**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

# ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំង បង្ការជំងឺកូវីដ-១៩ សំដៅបង្កើតឱ្យបាននូវ ភាពស៊ាំសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ក្នុងឆ្នាំ ២០២១

រៀបចំដោយ **ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**

ខែ ឧសភា ឆ្នាំ ២០២១

# មាតិកា

**I. សេចក្ដីផ្ដើម** ........ 1

**II. ការវាយតម្លៃយុទ្ធនាការចាក់វ៉ាក់សាំង-ដំណាក់កាលទី ១** ........ 2

**III. ក្របខណ្ឌរួមនៃផែនការយុទ្ធសាស្រ្ត** ........ 4

១. គោលបំណង និង គោលដៅ ........ 6

២. អភិក្រមនៃការអនុវត្តផែនការយុទ្ធសាស្រ្ត ........ 6

**IV. យុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ តាមតំបន់អាទិភាព** ........ 6

១. វិធីសាស្រ្តនៃការធ្វើអាទិភាវូបនីយកម្មតំបន់ ........ 6

២. ជំហាននៃការចាក់វ៉ាក់សាំងសម្រាប់តំបន់អាទិភាពខ្ពស់ ........ 9

៣. យន្តការគ្រប់គ្រងការអនុវត្ត ........ 10

៤. ការគ្រប់គ្រងហានិភ័យ ........ 11

**V. សេចក្ដីសន្និដ្ឋាន** ........ 12

**ឧបសម្ព័ន្ធទី ១** ........ 13

**ឧបសម្ព័ន្ធទី ២** ........ 14

**ឧបសម្ព័ន្ធទី ៣** ........ 21

## I. សេចក្តីផ្តើម

ជំងឺកូវីដ-១៩ បានឆ្លងរាលដាលដល់គ្រប់ប្រទេស និង ដែនដីទាំងអស់នៅលើសកលលោក ហើយបានបណ្តាលឲ្យមនុស្សប្រមាណ ១៥០ លាននាក់ ឆ្លងជំងឺ និង ប្រមាណជាង ៣ លាននាក់ បាត់បង់ជីវិត ។ បច្ចុប្បន្ន, ស្ថានភាពនៃការឆ្លងជំងឺកូវីដ-១៩ ក៏នៅតែបន្តវិវឌ្ឍយ៉ាងលឿន ជាពិសេស តាមរយៈការបំប្លែងខ្លួនជាប្រភេទវីរុសកូវីដ-១៩ ថ្មី (វីរុសបំប្លែងថ្មី) ដែលមានសមត្ថភាពចម្លង និង បង្ក គ្រោះថ្នាក់កាចសាហាវជាងមុនច្រើនដង ដល់អាយុជីវិតមនុស្ស ។ ក្នុងបរិការណ៍ដែលការព្យាបាលតាម បែបវេជ្ជសាស្ត្រនៅមិនទាន់មានភាពប្រាកដប្រជា, ប្រទេសជាច្រើនបានប្រើប្រាស់វិធានការសុខាភិបាល និងរដ្ឋបាលនានា រួមទាំងការបិទខ្ទប់តំបន់ ឬ ប្រទេសទាំងមូល ជាច្រើនលើកច្រើនសារ ។ ជាលទ្ធផល, វិធានការទាំងនេះបានចូលរួមចំណែកកាត់បន្ថយការឆ្លងរីករាលដាល និង ជួយសង្គ្រោះជីវិតប្រជា-ពលរដ្ឋ តែបានបង្កើតជាសម្ពាធសង្គម-សេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ លើប្រទេសទាំងនោះ ។ ទន្ទឹមនេះ, ក្នុងពេល ដែលការអភិវឌ្ឍវ៉ាក់សាំងបានឈានដល់ដំណាក់កាលនៃការដាក់ឲ្យប្រើប្រាស់, ប្រទេសទាំងអស់ក្នុង ពិភពលោក បានប្រកាន់យកវិធានការចាក់វ៉ាក់សាំងបង្កើតភាពស៊ាំសហគមន៍ ដើម្បីរួមចំណែកគ្រប់គ្រង ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និង ជំរុញសកម្មភាពសង្គម-សេដ្ឋកិច្ចឡើងវិញ ។

ក្នុងរយៈពេលជាង ១ ឆ្នាំ បន្ទាប់ពីជំងឺកូវីដ-១៩ បានផ្ទុះឡើងនៅកម្ពុជា, ទោះបីជារាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែងឥតឈប់ឈរ ក្នុងស្មារតីបុរេសកម្ម និង ម៉ឺងម៉ាត់ ដើម្បីគ្រប់គ្រងការហូរចូល និង ការផ្ទុះឡើងនូវព្រឹត្តិការណ៍សហគមន៍ជាបន្តបន្ទាប់ក្តី, ការឆ្លងរីករាលដាលជាចង្កោមនៅក្នុងសហគមន៍ ដែលបណ្តាលមកពីប្រភេទវីរុសបំប្លែងថ្មី ឬហៅថា «**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១**» បាន បង្កើតនូវសម្ពាធយ៉ាងធ្ងន់ធ្ងរមកលើប្រព័ន្ធសុខាភិបាលកម្ពុជា ព្រមទាំងបានអូសបន្លាយពេលវេលា និង បានពង្រីកវិសាលភាពនៃការឆ្លងជំងឺនេះ ។ គិតមកត្រឹមថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០២១, ប្រជាជន កម្ពុជាចំនួន ១៣ ៤០២ នាក់បានឆ្លងជំងឺនេះ ដែលក្នុងនោះ អ្នកជំងឺចំនួនត្រឹមតែ ៥ ១៥២ នាក់ បាន ជាសះស្បើយ ខណៈ ៩៣ នាក់ បានបាត់បង់ជីវិត ដោយសារជំងឺកូវីដ-១៩ ។

ក្នុងគោលបំណងកាត់ផ្តាច់ការឆ្លងរីករាលដាលនៅក្នុងរាជធានីភ្នំពេញ ក៏ដូចជាតាមបណ្តា ខេត្តនានា, រាជរដ្ឋាភិបាលកម្ពុជាប្រកាន់យកវិធានការដាច់ខាត តាមរយៈការបិទខ្ទប់រាជធានីភ្នំពេញ និង ក្រុងតាខ្មៅនៃខេត្តកណ្តាល ចាប់តាំងពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០២១ ក៏ដូចជាបិទខ្ទប់ភូមិ ឬ ឃុំ នានា នៅតាមបណ្តាខេត្ត ទៅតាមស្ថានភាពតម្រូវជាក់ស្តែង ។ វិធានការបិទខ្ទប់នេះ បាននាំមកនូវ ភាពជោគជ័យជាបឋម នោះគឺការកាត់ផ្តាច់ខ្សែរយៈនៃការចម្លងជំងឺកូវីដ-១៩ នៅក្នុងភូមិសាស្ត្របិទខ្ទប់ និង ការឆ្លងយឺត ឬ តិចតួច ពីភ្នំពេញទៅតាមបណ្តាខេត្តនានា ព្រមទាំងការកំណត់បាននូវតំបន់ទៅ តាមកម្រិតហានិភ័យ (ហានិភ័យខ្ពស់-ជាតំបន់ពណ៌ក្រហម, ហានិភ័យមធ្យម-ជាតំបន់ពណ៌លឿងទុំ និង ហានិភ័យទាប-ជាតំបន់ពណ៌លឿង) ក្នុងរាជធានីភ្នំពេញ និង ក្រុងតាខ្មៅ ដោយបានអនុញ្ញាត ឲ្យមានការធ្វើចរាចរណ៍ និង សកម្មភាពសេដ្ឋកិច្ចឡើងវិញ នៅក្នុងតំបន់ពណ៌លឿង ។

ជាមួយស្មារតីបុរេសកម្ម និង ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និង គតិបណ្ឌិត របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**, រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាច្រើន ដែលមានភាព-

ទន់ភ្លន់, តែម៉ឺងម៉ាត់ បត់បែនទៅតាមសភាពការណ៍ និង ទីតាំងភូមិសាស្ត្រជាក់ស្ដែង ។ រាជរដ្ឋាភិបាលក៏បានយល់ច្បាស់ដែរថា វិធានការនានា ដែលត្រូវបានដាក់ចេញកន្លងមក ក៏ដូចជានៅក្នុងពេលអនាគតនឹងមិនអាចលុបបំបាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ជារៀងរហូតបានទេ ។ ដូចគ្នានឹងប្រទេសដទៃទៀតដែរ ក្នុងពេលដែលការព្យាបាលតាមបែបវេជ្ជសាស្ត្រនៅមិនទាន់មានភាពប្រាកដប្រជា ព្រមជាមួយនឹងការយល់ដឹងអំពីសារៈសំខាន់នៃការចាក់វ៉ាក់សាំងបង្កើតភាពស៊ាំសហគមន៍ ដែលអាចនឹងជួយដល់ការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក៏ដូចជាអាចជួយកាត់បន្ថយនូវអត្រាចូលសម្រាកពេទ្យ និង អត្រាមរណភាពបណ្ដាលមកពីជំងឺកូវីដ-១៩ នេះ, រាជរដ្ឋាភិបាលបានសម្រេចចិត្តយ៉ាងត្រឹមត្រូវ និង ទាន់ពេល ក្នុងការកំណត់យកការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋ ដោយឥតគិតថ្លៃ និង ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត ជាវិធានការយុទ្ធសាស្ត្រគន្លឹះដ៏សំខាន់មួយ ដើម្បីរួមចំណែកគ្រប់គ្រងការឆ្លងរាលដាលជំងឺកូវីដ-១៩ និង ធានានូវការឈានយ៉ាងឆាប់រហ័សទៅរក **«ប្រក្រតីភាពថ្មី»** នៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជាទូទៅ និង កិច្ចដំណើរការនៃវិស័យសង្គម-សេដ្ឋកិច្ច ។ ដើម្បីគោលដៅនេះ, គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស បានរៀបចំឡើងនូវ **«ផែនការមេចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស»** ។

## II. ការវាយតម្លៃយុទ្ធនាការចាក់វ៉ាក់សាំង-ដំណាក់កាលទី ១

ជាមួយនឹងការកំណត់យកការចាក់វ៉ាក់សាំងជាវិធានការយុទ្ធសាស្ត្រ, រាជរដ្ឋាភិបាលក៏បានខិតខំប្រឹងប្រែងក្នុងការទិញវ៉ាក់សាំងផ្ទាល់ពីប្រទេសអ្នកផលិត និង ស្វែងរកជំនួយជាវ៉ាក់សាំងពីស្ថាប័នអន្តរជាតិនានា និង ពីប្រទេសជាមិត្ត ។ ជាផ្លែផ្កានៃកិច្ចខំប្រឹងប្រែងនេះ, កម្ពុជាបានក្លាយជាប្រទេសទីមួយ, ក្នុងចំណោមបណ្ដាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍, ដែលទទួលបានវ៉ាក់សាំងពីស្ថាប័នកូវ៉ាក់ ក៏ដូចជាទទួលបានជំនួយមនុស្សធម៌ជាវ៉ាក់សាំងពីមិត្តចិន និង ដែលបានអនុញ្ញាតឲ្យកម្ពុជាចាប់ផ្ដើមយុទ្ធនាការជាតិចាក់វ៉ាក់សាំង នៅដើមខែ កុម្ភៈ ឆ្នាំ ២០២១ ។ លើសពីនេះទៀត, វ៉ាក់សាំងដែលកម្ពុជាបានបញ្ជាទិញ ក៏បានមកដល់ជាហូរហែ ។ រហូតមកដល់ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០២១, កម្ពុជាទទួលបានវ៉ាក់សាំងសរុបចំនួន ៤ ០២៤ ០០០ ដូស ។

គោលបំណងនៃយុទ្ធនាការជាតិចាក់វ៉ាក់សាំងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងដំណាក់កាលទី ១ គឺបង្កើតភាពស៊ាំដល់អ្នកផ្ដល់សេវាជួរមុខទូទាំងប្រទេស ដែលរួមមាន បុគ្គលិកសុខាភិបាល, កងកម្លាំងប្រដាប់អាវុធ និង មន្ត្រីសាធារណៈ ព្រមទាំងក្រុមជនងាយរងគ្រោះមួយចំនួនទៀត ។ ក្នុងរយៈពេលត្រឹម ៣ ខែ, គិតចាប់ពីខែ កុម្ភៈ ដល់ខែ មេសា ឆ្នាំ ២០២១ នេះ, មន្ត្រីសាធារណៈជួរមុខ, កងកម្លាំងប្រដាប់អាវុធ, មន្ត្រីរាជការ និងប្រជាពលរដ្ឋចំនួនជាង ១,៣ លាននាក់ ទទួលបាននូវការចាក់វ៉ាក់សាំង។ ជារួម, យុទ្ធនាការជាតិចាក់វ៉ាក់សាំង-ដំណាក់កាលទី ១ ដែលគ្រោងនឹងត្រូវបញ្ចប់នាពេលខាងមុខដ៏ខ្លីនេះ បានប្រព្រឹត្តទៅក្នុងល្បឿនមួយគួរឲ្យកត់សម្គាល់ និង សម្រេចបានលទ្ធផលតាមការគ្រោងទុក ។

ឈរលើលទ្ធផលនៃយុទ្ធនាការជាតិចាក់វ៉ាក់សាំង-ដំណាក់កាលទី ១, យើងអាចវាយតម្លៃអំពីភាពខ្លាំង, ភាពខ្សោយ, កាលានុវត្តភាព និង ការគំរាមកំហែង នៅក្នុងយុទ្ធនាការកន្លងមកនេះ ដូចមានចែងក្នុងតារាងខាងក្រោម ៖

| ភាពខ្លាំង | ភាពខ្សោយ |
|---|---|
| • ការសម្រេចចិត្តបានយ៉ាងឆាប់រហ័ស ក្នុងការចាក់វ៉ាក់សាំង<br>• អ្នកបម្រើសេវាជួរមុខ បានទទួលការចាក់វ៉ាក់សាំងរួចចំនួនជាង ១,៣ លាននាក់<br>• ការប្រើប្រាស់កម្លាំងជាតិសរុប ដែលអាចចូលរួមអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំង៖<br>○ ក្រុមគ្រូពេទ្យជាតិ<br>○ កងកម្លាំងយោធា, ស៊ីវិល, កងទ័ព និងនគរបាលជួរមុខ, និង<br>○ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត និង អ្នកស្ម័គ្រ-ចិត្តក្នុងសហគមន៍ ។ | • ធនធានមានកម្រិត<br>• កង្វះខាតហេដ្ឋារចនាសម្ព័ន្ធក្នុងការប្រមូលប្រព័ន្ធទិន្នន័យ, ព័ត៌មានពាក់ព័ន្ធនឹងចំនួនអ្នកទទួលបានការចាក់វ៉ាក់សាំង នៅតាមបណ្ដាខេត្ត, និង<br>• កង្វះទីតាំង/ឃ្លាំងស្តង់ដារ (ប្រព័ន្ធត្រជាក់) សម្រាប់ស្តុកវ៉ាក់សាំង នៅតាមខេត្ត ឬជនបទ ។ |
| **កាលានុវត្តភាព** | **ការគំរាមកំហែង** |
| • ការប្ដេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំ ក្នុងការអនុ-វត្តយុទ្ធនាការចាក់វ៉ាក់សាំងទូទាំងប្រទេស<br>• កិច្ចសហការរបស់ប្រជាពលរដ្ឋទាំងអស់ក្នុងការអនុវត្តតាមវិធានការរបស់ក្រសួងសុខា-ភិបាល និង វិធានការនានារបស់រាជរដ្ឋាភិ-បាលកម្ពុជា<br>• កិច្ចសហការ និង ការចូលរួមស្ម័គ្រចិត្តក្នុងការចាក់វ៉ាក់សាំងរបស់ប្រជាពលរដ្ឋ និងវិស័យឯកជន, និង<br>• ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់នៅតាមមជ្ឈមណ្ឌលសេដ្ឋកិច្ចសំខាន់ៗ ។ | • លទ្ធភាពក្នុងការរកទិញ និង ការផ្គត់ផ្គង់វ៉ាក់-សាំង មិនបានតាមបំណងរំពឹងទុក<br>• បញ្ហាមួយចំនួនពាក់ព័ន្ធនឹងការតម្រូវផ្នែកបច្ចេកទេសរបស់វ៉ាក់សាំង<br>• កង្វះហេដ្ឋារចនាសម្ព័ន្ធរក្សាទុក និងដឹក-ជញ្ជូនវ៉ាក់សាំងគ្រប់ប្រភេទ ប្រកបដោយគុណភាព<br>• ជំងឺកូវីដ-១៩ ប្រភេទវីរុសបំប្លែងថ្មី ដែលអាចធ្វើឲ្យវ៉ាក់សាំងមិនសូវមានប្រសិទ្ធភាព, និង<br>• ប្រជាពលរដ្ឋ និងបុគ្គលិកក្នុងវិស័យឯកជនមួយចំនួន នៅមិនទាន់ស្ម័គ្រចិត្តទទួលការ-ចាក់វ៉ាក់សាំង ។ |

បទពិសោធន៍ និង មេរៀននៃការអនុវត្តក្នុងដំណាក់កាលទី ១ កន្លងមក នឹងត្រូវបានប្រើប្រាស់ជាធាតុចូលក្នុងការរៀបចំ, កែលម្អ និង ដាក់ចេញ នូវផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំង-ដំណាក់កាលទី ២ បន្តទៀត ។ នៅក្នុងបរិការណ៍ថ្មី ដែលអ្នកផ្តល់សេវាជួរមុខ រួមមានដូចជា បុគ្គលិកសុខាភិបាល, មន្ត្រី និង កងកម្លាំងប្រដាប់អាវុធភាគច្រើន បានទទួលការចាក់វ៉ាក់សាំងស្ទើរតែរួចអស់ហើយ និងបន្ថែមលើនេះ **«ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១»** បានផ្ទុះរីករាលដាលនៅក្នុងរាជធានីភ្នំពេញ ដែលជាបេះដូងនៃប្រទេស ព្រមទាំងបានបង្កផលប៉ះពាល់ដល់គ្រប់វិស័យសំខាន់ៗនៃសង្គម-សេដ្ឋកិច្ចជាតិ, រាជរដ្ឋាភិបាលមានភាពចាំបាច់ក្នុងការពិនិត្យកែសម្រួលអភិក្រមនៃការរៀបចំ

និង អនុវត្តយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ពី **ការចាក់វ៉ាក់សាំងទៅតាមប្រភេទក្រុមមនុស្សដែលងាយរងគ្រោះ, ប្រភេទនៃការងារ និង ស្ថានភាពសុខភាព** ទៅជា **ការចាក់វ៉ាក់សាំងជូនប្រជាជនគ្រប់រូប ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ សំដៅបង្កើតភាពស៊ាំសហគមន៍ឲ្យបានឆាប់នៅតំបន់អាទិភាពខ្ពស់ រួមបញ្ចូលនូវ រាជធានី និង តំបន់ទីប្រជុំជនធំៗ ដែលមានប្រជាពលរដ្ឋច្រើនកុះករធ្វើការ និង រស់នៅ និងដែលមានសារៈសំខាន់ខ្ពស់ខាងសង្គម-សេដ្ឋកិច្ច ក្នុងគោលដៅរួមចំណែកគ្រប់គ្រងឲ្យបាននូវការឆ្លងរាលដាលជំងឺកូវីដ-១៩, បញ្ចៀសនូវការអនុវត្តវិធានការបិទខ្ទប់ក្នុងទ្រង់ទ្រាយធំនាពេលអនាគត និង ធានាជារួមនូវនិរន្តរភាពនៃកិច្ចដំណើការជីវភាពសង្គម-សេដ្ឋកិច្ចរបស់ប្រទេស ។**

ជាមួយហេតុផលខាងលើ, រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវ **«ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើតឲ្យបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ក្នុងឆ្នាំ ២០២១»** ដែលជាការអនុវត្តដំណាក់កាលទី ២ បន្តពីយុទ្ធនាការចាក់វ៉ាក់សាំង-ដំណាក់កាលទី ១ ។ ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ នេះ នឹងផ្តោតលើ៖ ទី១)-ការចាក់វ៉ាក់សាំងជូនដល់ប្រជាជនគ្រប់រូប ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើង នៅក្នុងតំបន់អាទិភាពខ្ពស់; ទី២)-ការអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងឲ្យបានឆាប់រហ័សតាមចិរវេលាកំណត់ និងក្រោមការសម្របសម្រួល និង ការធ្វើសមកាលកម្មច្បាស់លាស់ រវាងផែនការសកម្មភាពចាក់វ៉ាក់សាំង និង កាលវិភាគនៃការរំពឹងទុកអំពីការមកដល់របស់វ៉ាក់សាំង និង កាលវិភាគនៃការបញ្ជាទិញ និង ការផ្គត់ផ្គង់វ៉ាក់សាំងថ្មីស្របតាមតម្រូវការជាក់ស្តែង; និង ទី៣)-ការអនុវត្តនូវការចាក់វ៉ាក់សាំងក្នុងលក្ខណៈជាយុទ្ធនាការជាតិតាមរយៈការប្រើប្រាស់កម្លាំងសរុប (រួមបញ្ចូលនូវមន្ត្រី-បុគ្គលិកគ្រប់ស្ថាប័នពាក់ព័ន្ធរបស់រដ្ឋ, អ្នកស្ម័គ្រចិត្ត និង ពេទ្យឯកជន) និង មធ្យោបាយសរុបរបស់ជាតិ ឲ្យសម្រេចបានឆាប់រហ័សតាមតែអាចធ្វើទៅរួច និងដោយធានាឲ្យបាននូវរបៀបរៀបរយ និង សណ្តាប់ធ្នាប់ ដើម្បីបង្ការការឆ្លងរាលដាលជំងឺកូវីដ-១៩ ពិសេសតាមរយៈគោលការណ៍នាំយកសេវាទៅកៀកបំផុតជូនប្រជាពលរដ្ឋ ។

## III. ក្របខណ្ឌរួមនៃផែនការយុទ្ធសាស្ត្រ

ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើតឲ្យបាននូវភាពស៊ាំសហគមន៍នៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា គឺជាវិធានការយុទ្ធសាស្ត្រគន្លឹះដ៏មានប្រសិទ្ធភាពមួយ ដែលត្រូវអនុវត្តគួបផ្សំជាមួយនឹងវិធានការចាំបាច់ផ្សេងទៀត ជាពិសេសវិធានការ **«៣-កុំ និង ៣-ការពារ»** ដើម្បីធានាឲ្យកម្ពុជាអាចបន្តដំណើរអភិវឌ្ឍន៍ទៅមុខ លើគន្លងនៃ **«ប្រក្រតីភាពថ្មី»** ។ ក្របខណ្ឌរួមនៃផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើតឲ្យបាននូវភាពស៊ាំសហគមន៍នៅកម្ពុជា រួមបញ្ចូលនូវសមាសធាតុគន្លឹះសំខាន់ៗ ដូចមានបង្ហាញក្នុងរូបភាពទី ១ ខាងក្រោម ៖

## រូបភាពទី ១: ផែនការយុទ្ធសាស្ត្រចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើតឱ្យបាន នូវភាពស៊ាំសហគមន៍នៅកម្ពុជា







- ការគណនាចំនួនដូស គឺផ្អែកលើចំនួនប្រជាជនដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ដែលត្រូវទទួលបានវ៉ាក់សាំងកូវីដ-១៩ គ្រប់ៗគ្នា។ ការគណនានេះ មិនទាន់បានដកចេញចំនួនវ៉ាក់សាំងកូវីដ-១៩ ដែលបានចាក់ជូនប្រជាពលរដ្ឋរួចហើយនោះទេ ដែលមានចំនួន ១,៣២៩,៤៣៣ នាក់ (គិតត្រឹមថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២១)។ ដូច្នេះ, តំបន់នីមួយៗ, នៅពេលអនុវត្ត, ត្រូវដកចេញនូវចំនួនប្រជាពលរដ្ឋដែលបានទទួលវ៉ាក់សាំងកូវីដ-១៩ រួចហើយ ។
- ការកំណត់នូវជំហាន និង បិរវេលាខាងលើនេះ មានលក្ខណៈជាការចង្អុលបង្ហាញ ដើម្បីងាយប៉ាន់ប្រមាណលទ្ធភាពក្នុងការអនុវត្តប៉ុណ្ណោះ។ ដោយឡែក, ការអនុវត្តជាក់ស្តែង អាចមានវិសាលភាព និងល្បឿនខុសពីជំហាន និង បិរវេលាចង្អុលបង្ហាញខាងលើ អាស្រ័យ, ម្យ៉ាង, លើសមត្ថភាពក្នុងការអនុវត្តផែនការចាក់វ៉ាក់សាំង; និងម្យ៉ាងទៀត, លើបរិមាណ និង ល្បឿននៃការទទួលបានវ៉ាក់សាំង ។
- ទិន្នន័យជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ។

## ១. គោលបំណង និង គោលដៅ

**«ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើតឲ្យបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ក្នុងឆ្នាំ ២០២១»** គឺជាសមាសភាគគន្លឹះដ៏ចម្បងដែលចូលរួមបម្រើឲ្យគោលបំណងនៃ **«ការបង្កើតភាពស៊ាំសហគមន៍ទៅនឹងជំងឺកូវីដ-១៩ នៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា»** ។

គោលដៅនៃផែនការយុទ្ធសាស្ត្រនេះ គឺ **«បង្កើតភាពស៊ាំសង្គម-សេដ្ឋកិច្ច តាមរយៈការចាក់វ៉ាក់សាំងបង្កើតភាពស៊ាំសហគមន៍នៅក្នុងតំបន់អាទិភាពខ្ពស់ រួមមាន រាជធានី និង ទីរួមខេត្ត ព្រមទាំងតំបន់ទីប្រជុំជនសំខាន់ៗ ដែលមានប្រជាពលរដ្ឋច្រើនកុះករ ធ្វើការ និង រស់នៅ និងដែលមានសារៈសំខាន់ខ្ពស់ខាងសង្គម-សេដ្ឋកិច្ច សំដៅរួមចំណែកគ្រប់គ្រងឲ្យបាននូវការឆ្លងរាលដាលជំងឺកូវីដ-១៩, បញ្ចៀសការបិទខ្ទប់ក្នុងទ្រង់ទ្រាយធំនាពេលអនាគត និង ធានាជារួមនូវនិរន្តរភាពនៃកិច្ចដំណើរការជីវភាពសង្គម-សេដ្ឋកិច្ចជាតិ»** ។

## ២. អភិក្រមនៃការអនុវត្តផែនការយុទ្ធសាស្ត្រ

ដើម្បីសម្រេចគោលដៅខាងលើ, ការអនុវត្តផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងនេះ នឹងត្រូវបានអនុវត្តអនុលោមតាមអភិក្រម **«ផ្កាវីក»** ដោយចាប់ផ្តើមពីយុទ្ធនាការចាក់វ៉ាក់សាំងពីចំណុចកណ្តាលនៃប្រទេស គឺផ្តើមចេញពីរាជធានីភ្នំពេញ និង តំបន់ទីប្រជុំជនសំខាន់ៗជុំវិញរាជធានី ហើយពង្រីកជាជំហានៗទៅកាន់តំបន់ផ្សេងទៀត តាមលំដាប់លំដោយនៃការធ្វើអាទិភាវូបនីយកម្ម ។ កម្ពុជានឹងត្រូវបានបែងចែកជា ៣ តំបន់ គឺតំបន់អាទិភាពខ្ពស់, តំបន់អាទិភាពមធ្យម និង តំបន់អាទិភាពទាប ។ **អនុលោមតាមអភិក្រម «ផ្កាវីក» យុទ្ធនាការជាតិចាក់វ៉ាក់សាំងនៅក្នុងតំបន់អាទិភាពខ្ពស់ ត្រូវតែបញ្ចប់ឱ្យបាននៅក្នុងឆ្នាំ ២០២១, កាន់តែឆាប់ កាន់តែប្រសើរ** ។

# IV. យុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ តាមតំបន់អាទិភាព

## ១. វិធីសាស្ត្រនៃការធ្វើអាទិភាវូបនីយកម្មតំបន់

ការកំណត់តំបន់អាទិភាពនៃការចាក់វ៉ាក់សាំង, ដូចបង្ហាញក្នុងរូបភាពទី ២ ខាងក្រោម, ប្រើប្រាស់នូវសូចនាករគន្លឹះចំនួន ៣ ជាមូលដ្ឋាន ដែលក្នុងនោះរួមមាន ៖

- **ដង់ស៊ីតេប្រជាជន** : ជាមូលដ្ឋានដំបូងក្នុងការកំណត់ជាតំបន់អាទិភាព ពីព្រោះ ក្រុង/ស្រុក/ខណ្ឌ ដែលមានមនុស្សរស់នៅកកកុញងាយនឹងឆ្លងជំងឺ និង ក៏ជាកន្លែងដែលមានសកម្មភាពសេដ្ឋកិច្ចខ្ពស់ផងដែរ ។ ក្រុង/ស្រុក/ខណ្ឌ ដែលមានដង់ស៊ីតេប្រជាជនយ៉ាងហោចណាស់ ៣០០ នាក់ក្នុងមួយគីឡូម៉ែត្រក្រឡា ត្រូវបានចាត់ទុកជាតំបន់អាទិភាពខ្ពស់, ពី ៣០០-១០០ នាក់ក្នុងមួយគីឡូម៉ែត្រក្រឡា ជាតំបន់អាទិភាពមធ្យម និង ក្រោម ១០០ នាក់ ក្នុងមួយគីឡូម៉ែត្រក្រឡា ជាតំបន់អាទិភាពទាប ។
- **ភាគរយនៃចំនួនប្រជាជនប្រកបរបរមិនមែនកសិកម្ម**: ប្រជាជនមានមុខរបរក្រៅពីកសិកម្មមានសកម្មភាពច្រើន, ធ្វើដំណើរច្រើន និង ចេញចូលទៅ ក្រុង/ស្រុក/ខណ្ឌ ដទៃច្រើនដែរ ។ ម្យ៉ាងវិញ

ទៀត, តំបន់ដែលមានប្រជាជនប្រភេទនេះច្រើន ក៏មានសកម្មភាពមានតម្លៃបន្ថែម និង មាន ផលិតភាពខ្ពស់ផងដែរ ។ ក្រុង/ស្រុក/ខណ្ឌ ដែលមានភាគរយប្រជាជនប្រកបរបរមិនមែន កសិកម្ម លើសពី ៥០% ត្រូវបានចាត់ជាតំបន់អាទិភាពខ្ពស់, ពី ៥០%-២៥% ត្រូវបានចាត់ជា តំបន់អាទិភាពមធ្យម និង ទាបជាង ២៥% ត្រូវបានចាត់ជាតំបន់អាទិភាពទាប ។

- **សន្ទស្សន៍សក្តានុពលសេដ្ឋកិច្ច** : សន្ទស្សន៍នេះ គឺជាបន្សំនៃសូចនាករប្រាំ រួមមាន រយៈពេលធ្វើដំណើរទៅទីផ្សារ, ដង់ស៊ីតេផ្លូវ, ចំនួនក្រុមហ៊ុន, ភាគរយនៃប្រជាជនរស់នៅទីប្រជុំជន, និងអត្រាបញ្ចប់ការសិក្សា ។ សន្ទស្សន៍នេះ ត្រូវបានចែកជាប្រាំក្រុម គឺ ខ្ពស់បំផុត (១០០-៦០), ខ្ពស់ (៦០-៥៥), មធ្យម (៥៥-៤៥), ទាប (៤៥-៤០) និង ទាបបំផុត (៤០-០០) ។

ទោះជាយ៉ាងនេះក្តី, ការជ្រើសរើស ក្រុង/ស្រុក/ខណ្ឌ អាទិភាពជាក់ស្តែង មិនផ្អែកទាំងស្រុងទៅលើលក្ខណៈវិនិច្ឆ័យទាំងបីខាងលើទាំងស្រុងនោះទេ ពីព្រោះមិនទាន់បានគិតបញ្ចូលនូវអន្តរសកម្មរវាង ក្រុង/ស្រុក/ខណ្ឌ នីមួយៗ, ភាពក្បែរខាងគ្នា និង ករណីកំពុងកើតឡើងនៃជំងឺកូវីដ-១៩ ។ ទីរួមខេត្តទាំងអស់ ត្រូវបានចាត់ទុកជាតំបន់ស្នូលនៃរដ្ឋបាល ទោះបីជាទីរួមខេត្តខ្លះតូច និង មិនមានសក្តានុពលសេដ្ឋកិច្ចខ្ពស់ជាង ក្រុង/ស្រុក/ខណ្ឌ នៃខេត្តមួយចំនួនក្តី ។ ការសម្រេចលើ ក្រុង/ស្រុក/ខណ្ឌ អាទិភាពអាចនឹងត្រូវពិនិត្យកែសម្រួលឡើងវិញតាមការចាំបាច់ ដើម្បីធានាឲ្យមានភាពសមហេតុផល និង សម្រួលដល់យុទ្ធនាការចាក់វ៉ាក់សាំងផងដែរ ។ ដោយផ្អែកជាគោលលើសូចនាករទាំង ៣ ខាងលើនេះ, អាទិភាពនៃតំបន់ទាំងអស់ទូទាំងប្រទេស ត្រូវបានចែកជាបីក្រុម គឺ : តំបន់អាទិភាពខ្ពស់, តំបន់អាទិភាពមធ្យម និង តំបន់អាទិភាពទាប ។

ជាលទ្ធផល, **តំបន់អាទិភាពខ្ពស់** គ្របសោបយក ក្រុង/ស្រុក/ខណ្ឌ ចំនួន ៧០ នៅទូទាំងប្រទេស ក្នុងនោះ គ្របដណ្តប់ទាំងរាជធានីភ្នំពេញ និង ខេត្តកណ្តាលទាំងមូល, តំបន់សក្តានុពលសេដ្ឋកិច្ចនៅក្នុងក្រុងព្រះសីហនុ, ក្រុងបោយប៉ែត និង ក្រុងបាវិត, ទីរួមខេត្តទាំងអស់នៃបណ្តាខេត្តនានា និង បណ្តាស្រុកសំខាន់ៗដែលស្ថិតនៅជុំវិញខេត្តកណ្តាល ។ ចំនួនប្រជាជនដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ កំពុងរស់នៅក្នុងតំបន់ទាំងនោះ សរុបមាន ៤,៩ លាននាក់ ដែលស្មើនឹង ៤៨,៥៧ % នៃប្រជាជនដែលមានអាយុលើសពី ១៨ ឆ្នាំឡើង នៅទូទាំងប្រទេស ។ **ដូច្នេះ, ការចាក់វ៉ាក់សាំងដល់ប្រជាជនចាប់ពីអាយុ ១៨ ឆ្នាំ ឲ្យបានគ្រប់គ្នា នៅក្នុងតំបន់អាទិភាពខ្ពស់នេះ នឹងអាចបង្កើតបានជារួមនូវភាពស៊ាំសង្គម-សេដ្ឋកិច្ចសម្រាប់ទូទាំងប្រទេស ។**

**តំបន់អាទិភាពមធ្យម** ត្រូវបានកំណត់យក ក្រុង/ស្រុក/ខណ្ឌ ចំនួន ៦៤ នៅទូទាំងប្រទេស ។ ចំនួនប្រជាជនដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ កំពុងរស់នៅក្នុងតំបន់ទាំងនោះ សរុបមាន ២,៨ លាននាក់ ។ **តំបន់អាទិភាពទាប** ត្រូវបានកំណត់យក ក្រុង/ស្រុក/ខណ្ឌ ចំនួន ៦៩ នៅទូទាំងប្រទេស ។ ចំនួនប្រជាជនដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ កំពុងរស់នៅក្នុងតំបន់ទាំងនោះ សរុបមាន ២,៣ លាននាក់ ។

រូបភាពទី ២ បង្ហាញនូវផែនទីរួមនៃការធ្វើអាទិភាវូបនីយកម្មតំបន់ ផ្អែកលើវិធីសាស្ត្រដែលបានរៀបរាប់ខាងលើ ហើយតំបន់នីមួយៗ ត្រូវបានរំលេចដោយពណ៌ផ្សេងៗគ្នា ។ តំបន់អាទិភាពខ្ពស់ មានពណ៌ក្រហម, តំបន់អាទិភាពមធ្យម មានពណ៌លឿងទុំ និង តំបន់អាទិភាពទាប មានពណ៌បៃតង ។

## រូបភាពទី ២: យុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ តាមតំបន់អាទិភាព សំដៅបង្កើតឱ្យបាននូវភាពស៊ាំសហគមន៍នៅកម្ពុជា

(បច្ចុប្បន្នភាពនៃផែនទី គិតត្រឹមថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០២១)




**កំណត់សម្គាល់**

**ចំនួនប្រជាជនដែលត្រូវទទួលការចាក់វ៉ាក់សាំងតាមតំបន់អាទិភាពជាជំហានៗ តាមលំដាប់អាទិភាពរូបនីយកម្ម (ចាប់ពីអាយុ ១៨ ឆ្នាំឡើង)**

- តំបន់អាទិភាពខ្ពស់ = 4,925,605 នាក់ (9,851,210 ដូស)
  - 1 ជំហានទី ១ = 2,481,652 នាក់ (4,963,304 ដូស) (ចាក់វ៉ាក់សាំងពីខែ ឧសភា ពាក់កណ្ដាលខែ កក្កដា ២០២១)
  - 2 ជំហានទី ២ = 2,332,383 នាក់ (4,304,766 ដូស) (ចាក់វ៉ាក់សាំងពីពាក់កណ្ដាលខែ កក្កដា កញ្ញា ២០២១)
  - 3 ជំហានទី ៣ = 441,570 នាក់ (883,140 ដូស) (ចាក់វ៉ាក់សាំងក្នុងខែ តុលា វិច្ឆិកា ២០២១)
- តំបន់អាទិភាពមធ្យម = 2,888,510 នាក់ (5,777,020 ដូស) (ចាប់ផ្ដើមចាក់វ៉ាក់សាំងនៅចុងឆ្នាំ ២០២១)
- តំបន់អាទិភាពទាប = 2,326,790 នាក់ (4,653,580 ដូស) (ចាប់ផ្ដើមចាក់វ៉ាក់សាំងនៅដើមឆ្នាំ ២០២២)
- **សរុបទាំង ៣ តំបន់ = 10,140,905 នាក់ (20,281,810 ដូស)**

**កាលវិភាគរំពឹងទុកនៃការទទួលបានវ៉ាក់សាំងកូវីដ-១៩ សម្រាប់ឆ្នាំ ២០២១ (គិតត្រឹមថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០២១)**

| មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|
| - | 600,000 ដូស | 2,524,000 ដូស | 900,000 ដូស | 3,000,000 ដូស | 3,000,000 ដូស | 1,000,000 ដូស | 1,000,000 ដូស | 1,500,000 ដូស | - | - | - | **13,524,000 ដូស** |

- ការគណនាចំនួនដូស គឺផ្អែកលើចំនួនប្រជាជនដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ដែលត្រូវទទួលបានវ៉ាក់សាំងកូវីដ-១៩ គ្រប់ៗគ្នា ។ ការគណនានេះ មិនទាន់បានដកចេញចំនួនវ៉ាក់សាំងកូវីដ-១៩ ដែលបានចាក់ជូនប្រជាពលរដ្ឋរួចហើយនោះទេ ដែលមានចំនួន ១,៣២៩,៤៣៣ នាក់ (គិតត្រឹមថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២១) ។ ដូច្នេះ តំបន់នីមួយៗ, នៅពេលអនុវត្ត, ត្រូវដកចេញនូវចំនួនប្រជាពលរដ្ឋដែលបានទទួលវ៉ាក់សាំងកូវីដ-១៩ រួចហើយ ។
- ការកំណត់នូវជំហាន និង ចំរវេលាខាងលើនេះ មានលក្ខណៈជាការចង្អុលបង្ហាញ ដើម្បីងាយប៉ាន់ប្រមាណលទ្ធភាពក្នុងការអនុវត្តប៉ុណ្ណោះ ។ ដោយឡែក, ការអនុវត្តជាក់ស្ដែង អាចមានអាទិភាព និង ល្បឿនខុសពីជំហាន និង ចំរវេលាចង្អុលបង្ហាញខាងលើ អាស្រ័យ, ម្យ៉ាង, លើសមត្ថភាពក្នុងការអនុវត្តផែនការចាក់វ៉ាក់សាំង; និងម្យ៉ាងទៀត, លើបរិមាណ និង ល្បឿននៃការទទួលបានវ៉ាក់សាំង ។
- ទិន្នន័យជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ។

## ២. ជំហាននៃការចាក់វ៉ាក់សាំងសម្រាប់តំបន់អាទិភាពខ្ពស់

យោងតាមផែនការលទ្ធកម្មវ៉ាក់សាំងជាធរមាន, កម្ពុជារំពឹងថានឹងទទួលបានវ៉ាក់សាំងបន្ថែម ៧ លានដូស ពីខែ ឧសភា ដល់ខែ កក្កដា និង ២,៥ លានដូសទៀត ពីខែ សីហា ដល់ ខែ កញ្ញា ។ វ៉ាក់សាំងដែលរំពឹងថានឹងទទួលបាននេះ មានចំនួនគ្រប់គ្រាន់ ដើម្បីសម្រេចឲ្យបាននូវ **«យុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ នៅតំបន់អាទិភាពខ្ពស់ សំដៅបង្កើតឲ្យបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ចនៅកម្ពុជា នៅក្នុងឆ្នាំ ២០២១»** ។ លើមូលដ្ឋាននេះ និង ដោយយោងលើលទ្ធផលនៃយុទ្ធនាការចាក់វ៉ាក់សាំងកន្លងមក, ការចាក់វ៉ាក់សាំងបង្កើតភាពស៊ាំនៅក្នុងតំបន់អាទិភាពខ្ពស់ នឹងត្រូវរៀបចំឡើងជា ៣ ជំហាន អនុលោមតាមអភិក្រម **«ផ្កាវីក»** ចាប់ផ្ដើមចេញពីរាជធានីភ្នំពេញ ដែលជាបេះដូងនៃប្រទេស ហើយពង្រីកចេញទៅតាមភាពសំខាន់នៃតំបន់ និង ភាពប្រទាក់ក្រឡាគ្នានៃសង្គម-សេដ្ឋកិច្ចនៅក្នុងតំបន់អាទិភាពខ្ពស់ទាំងអស់ ដូចខាងក្រោម ៖

- **ជំហានទី ១-ពីខែ ឧសភា ដល់ពាក់កណ្ដាលខែ កក្កដា ឆ្នាំ ២០២១** : ផ្ដោតលើក្រុមប្រជាជនទាំងអស់ ចាប់ពីអាយុ ១៨ ឆ្នាំឡើង ដែលធ្វើការ និង រស់នៅក្នុងរាជធានីភ្នំពេញ និងខេត្តកណ្ដាលទាំងមូល (គ្របដណ្ដប់ប្រមាណ ២៥ ក្រុង/ស្រុក/ខណ្ឌ) ដែលមានចំនួនសរុបជិត ២,៥ លាននាក់ និង ត្រូវការវ៉ាក់សាំងចំនួនជិត ៥ លានដូស;
- **ជំហានទី ២-ពីពាក់កណ្ដាលខែ កក្កដា ដល់ខែ កញ្ញា ឆ្នាំ ២០២១** : ផ្ដោតលើក្រុមប្រជាជនចាប់ពីអាយុ ១៨ ឆ្នាំឡើង ដែលធ្វើការ និង រស់នៅ ក្នុងខេត្តចំនួន ១១ គ្របដណ្ដប់ ៣៣ ក្រុង/ស្រុក (តាកែវ, កំពង់ស្ពឺ, កំពង់ឆ្នាំង, កំពង់ចាម, ព្រៃវែង, ក្រុងព្រះសីហនុ, ស្វាយរៀង, សៀមរាប, បន្ទាយមានជ័យ, កែប និង កំពត) ដែលមានចំនួនសរុបជាង ២ លាននាក់ និង ត្រូវការវ៉ាក់សាំងចំនួនជាង ៤ លានដូស;
- **ជំហានទី ៣-ពីខែ តុលា ដល់ខែ វិច្ឆិកា ឆ្នាំ ២០២១** : ផ្ដោតលើក្រុមប្រជាជន ចាប់ពីអាយុ ១៨ ឆ្នាំឡើង ដែលធ្វើការ និង រស់នៅ ក្នុងខេត្តចំនួន ១២ គ្របដណ្ដប់ ១២ ក្រុង/ស្រុក (កោះកុង, ឧត្ដរមានជ័យ, ប៉ៃលិន, ពោធិ៍សាត់, បាត់ដំបង, ស្ទឹងត្រែង, ត្បូងឃ្មុំ, រតនគិរី, ព្រះវិហារ, កំពង់ធំ, ក្រចេះ និង មណ្ឌលគិរី) ដែលមានចំនួនសរុបជាង ៤,៤ សែននាក់ និង ត្រូវការវ៉ាក់សាំងចំនួនប្រមាណ ៩ សែនដូស ។

ដោយសារវ៉ាក់សាំងដែលរំពឹងថានឹងមកដល់កម្ពុជានៅក្នុងខែ ឧសភា និង មិថុនា មានចំនួនលើសពីតម្រូវការជាក់ស្ដែងសម្រាប់ប្រើប្រាស់នៅក្នុងជំហានទី ១, ការចាក់វ៉ាក់សាំងជំហានទី ២ នៅតំបន់មួយចំនួន ដែលមានការផ្ទុះរីករាលដាលខ្លាំង ដូចជា ក្រុងព្រះសីហនុ និង ក្រុងប៉ោយប៉ែត ឬ នៅតំបន់ដែលមានសក្ដានុពលសេដ្ឋកិច្ចខ្ពស់ ដូចជា ក្រុងសៀមរាប, បាវិត និង កែប ក៏អាចនឹងចាប់ផ្ដើមទន្ទឹមគ្នានឹងជំហានទី ១ ផងដែរ អាស្រ័យលើលទ្ធភាព និង សមត្ថភាពនៅក្នុងការរៀបចំចាត់ចែងកម្លាំងដើម្បីអនុវត្ត ។ រីឯតំបន់ដទៃទៀតដែលមិនបានរៀបរាប់មុននេះ អាចនឹងត្រូវចាប់ផ្ដើមយុទ្ធនាការចាក់វ៉ាក់សាំងទៅតាមការកំណត់ខាងលើ គឺពីពាក់កណ្ដាលខែ កក្កដា ដល់ខែ កញ្ញា ឬអាចចាប់ផ្ដើមលឿនជាងកាលកំណត់ ក្នុងករណីដែលការចាក់វ៉ាក់សាំងនៅក្នុងជំហានទី ១ ចប់បានលឿន និង មាន

នៅសល់វ៉ាក់សាំងសម្រាប់ចាក់បន្តទៀត ។ **គួរគូសបញ្ជាក់បន្ថែមថា ជាគោលការណ៍, ការកំណត់នូវជំហាន និង ចិរវេលាខាងលើនេះ មានលក្ខណៈជាការចង្អុលបង្ហាញ ដើម្បីងាយប៉ាន់ប្រមាណលទ្ធភាពក្នុងការអនុវត្តប៉ុណ្ណោះ ។ ដោយឡែក, ការអនុវត្តជាក់ស្តែងអាចមានវិសាលភាព និង ល្បឿន ខុសពីជំហាន និង ចិរវេលាចង្អុលបង្ហាញខាងលើ អាស្រ័យ, ម៉្យាង, លើសមត្ថភាពក្នុងការអនុវត្តផែនការចាក់វ៉ាក់សាំង; និងម៉្យាងទៀត, លើបរិមាណ និង ល្បឿននៃការទទួលបានវ៉ាក់សាំង ។ ជាគោលដៅរួមសម្រាប់យុទ្ធនាការជាតិចាក់វ៉ាក់សាំងនៅក្នុងតំបន់អាទិភាពខ្ពស់នេះ គឺត្រូវសម្រេចឲ្យបាននៅក្នុងឆ្នាំ ២០២១ នេះ, កាន់តែឆាប់ កាន់តែប្រសើរ ។**

ដោយឡែក, ការចាក់វ៉ាក់សាំងជូនប្រជាជន ចាប់ពីអាយុ ១៨ ឆ្នាំឡើង ដែលធ្វើការ និង រស់នៅក្នុងតំបន់អាទិភាពមធ្យម និងទាប នឹងត្រូវរៀបចំលម្អិតទៅតាមក្រោយ ដោយអាស្រ័យលើផែនការនៃការបញ្ជាទិញវ៉ាក់សាំង និង ការវិវឌ្ឍនៃជំងឺកូវីដ-១៩ ក៏ដូចជាអាស្រ័យលើលទ្ធផលនៃការអនុវត្តយុទ្ធនាការជាតិចាក់វ៉ាក់សាំងជូនប្រជាជន ចាប់ពីអាយុ ១៨ ឆ្នាំឡើង ដែលធ្វើការ និង រស់នៅ ក្នុងតំបន់អាទិភាពខ្ពស់ ។

## ៣. យន្តការគ្រប់គ្រងការអនុវត្ត

ការអនុវត្តសម្រេចឲ្យបាន **ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំង** នេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់ គឺអាស្រ័យលើការប្តេជ្ញាចិត្ត និង ការគាំទ្រពេញលេញ ពីសំណាក់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ក៏ដូចជាការចូលរួមពីសំណាក់ក្រសួង-ស្ថាប័នពាក់ព័ន្ធគ្រប់ជាន់ថ្នាក់, អាជ្ញាធរមូលដ្ឋាន, បុគ្គលិកសុខាភិបាល (រដ្ឋ និង ឯកជន), កងកម្លាំងប្រដាប់អាវុធ និង ប្រជាពលរដ្ឋខ្លួនឯងក្នុងការអនុវត្ត ស្របតាមតួនាទី, ភារកិច្ច និង ការទទួលខុសត្រូវរៀងៗខ្លួន ។ **ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំង** នឹងត្រូវស្ថិតនៅក្រោមការដឹកនាំបញ្ជា និង ការគ្រប់គ្រងផ្ទាល់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងឋានៈជាអគ្គមេបញ្ជាការ ដោយមាន : (១)-គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស **(គ.វ.ក.១៩)** ជាសេនាធិការបច្ចេកទេស ទទួលបន្ទុកសម្របសម្រួលរួម លើការងាររៀបចំផែនការលម្អិតសម្រាប់អនុវត្ត និង លើការងារអនុវត្ត ឈរលើអភិក្រមនៃការប្រើប្រាស់កម្លាំងសរុប (មន្ត្រី-បុគ្គលិកគ្រប់ស្ថាប័នពាក់ព័ន្ធរបស់រដ្ឋ, អ្នកស្ម័គ្រចិត្ត និងពេទ្យឯកជន) និង មធ្យោបាយសរុបរបស់ជាតិ និងដោយធានាឲ្យបានរបៀបរៀបរយ និងសណ្តាប់ធ្នាប់ ដើម្បីបង្ការការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ពិសេសតាមរយៈគោលការណ៍នាំយកសេវាទៅកៀកបំផុតជូនប្រជាពលរដ្ឋ; និង (២)-ក្រុមការងារអន្តរក្រសួងទទួលបន្ទុកការចរចា និង ការពិគ្រោះយោបល់ទិញវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជាសេនាធិការបច្ចេកទេស ក្នុងការរៀបចំកម្មវិធីទិញ និង ផ្គត់ផ្គង់វ៉ាក់សាំងដោយសម្របសម្រួល និង ធ្វើសមកាលកម្ម ឲ្យបានស៊ីចង្វាក់គ្នាជាមួយនឹងការរៀបចំ និង ការអនុវត្តផែនការចាក់វ៉ាក់សាំង ។

ទោះបីជាការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ត្រូវផ្តោតទៅលើល្បឿននៃការចាក់វ៉ាក់សាំង និងចំនួនប្រជាពលរដ្ឋដែលត្រូវទទួលបាននូវការចាក់វ៉ាក់សាំងក៏ដោយ, ក៏គុណភាពនៃសេវា នៅតែមានសារៈសំខាន់ជាចម្បង ដែលទាមទារនូវការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់អ្នកអនុវត្ត ។ អាទិភាពខ្ពស់

ក៏គប្បីត្រូវបានផ្តល់ផងដែរ ទៅលើការគ្រប់គ្រងទិន្នន័យ (ដោយត្រូវចាប់ផ្តើមពីវិធីសាស្ត្រសាមញ្ញងាយស្រួល សម្រាប់រៀបចំបញ្ចូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានធំ និង គ្រប់ជ្រុងជ្រោយ តាមក្រោយ), ការរាយការណ៍ទិន្នន័យរបស់ប្រជាពលរដ្ឋដែលបានទទួលនូវការចាក់វ៉ាក់សាំងរួច និង ការគ្រប់គ្រងស្តុកវ៉ាក់សាំងប្រកបដោយសុក្រឹតភាព ។ល។

## ៤. ការគ្រប់គ្រងហានិភ័យ

ភាពមិនប្រាកដប្រជា និង ការវិវត្តលឿននៃជំងឺកូវីដ-១៩ រួមជាមួយនឹងភាពមានកម្រិត និង ភាពស្មុគស្មាញនៃការផ្គត់ផ្គង់វ៉ាក់សាំង អាចបង្កជាហានិភ័យដែលបណ្តាលឲ្យប៉ះពាល់ ដោយផ្ទាល់ ឬ ដោយប្រយោល ដល់ការអនុវត្ត **ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំង** ។ ការណ៍នេះ ទាមទារឲ្យរាជរដ្ឋាភិបាលកម្ពុជាមានភាពបុរេសកម្ម ដោយត្រូវកំណត់ និង គ្រប់គ្រងហានិភ័យធំៗ ដែលអាចបង្កឲ្យមានភាពបរាជ័យក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ។ ជារួម, កត្តាហានិភ័យធំៗចំនួន ៣ សម្រាប់ការអនុវត្ត **ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំង** នេះ ត្រូវបានកំណត់ ដូចខាងក្រោម ៖

**(១).ការទទួលបានវ៉ាក់សាំងមិនគ្រប់តាមតម្រូវការ** : ភាពមានកម្រិតនៃការផ្គត់ផ្គង់វ៉ាក់សាំង និង តម្រូវការខ្ពស់ពីបណ្តាប្រទេសនានានៅទូទាំងពិភពលោក អាចបង្កឲ្យមានហានិភ័យ ក្នុងការទទួលបានវ៉ាក់សាំង ដើម្បីបំពេញតម្រូវការជាក់ស្តែងរបស់កម្ពុជា ។ បន្ថែមលើនេះ, ភាពស្មុគស្មាញនៃបញ្ហាបច្ចេកទេសក្នុងការគ្រប់គ្រង និង ផ្គត់ផ្គង់វ៉ាក់សាំង ក៏អាចបង្កឲ្យមានភាពយឺតយ៉ាវ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ឲ្យសម្រេចបាន នៅក្នុងឆ្នាំ ២០២១ យ៉ាងឆាប់តាមតែអាចធ្វើបានផងដែរ ។ ការណ៍នេះ ទាមទារឲ្យរាជរដ្ឋាភិបាលខិតខំធានារកប្រភពសម្រាប់ទិញ និង ផ្គត់ផ្គង់វ៉ាក់សាំងឲ្យបានគ្រប់គ្រាន់ តាមតម្រូវការ និង តាមកាលកំណត់ ព្រមទាំងខិតខំកសាងសមត្ថភាពសម្រាប់ត្រៀមដោះស្រាយបញ្ហាបច្ចេកទេសនានាពាក់ព័ន្ធនឹង ការគ្រប់គ្រង, ការបែងចែក, ការដឹកជញ្ជូន និង ការថែរក្សាវ៉ាក់សាំង ជាដើម ដែលអាចកើតមានឡើងជាយថាហេតុ ។ យ៉ាងណាមិញ, ការសម្រេចចិត្តដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ក្នុងការចាប់យកដៃគូយុទ្ធសាស្ត្រជាមួយមិត្តចិន ធ្វើជាស្នូលសម្រាប់ការស្វះស្វែងរកទិញវ៉ាក់សាំង និង ទទួលបានជំនួយវ៉ាក់សាំង បានក្លាយជាកត្តាគន្លឹះមួយដ៏សំខាន់ផងដែរ ដែលអាចជួយដោះស្រាយហានិភ័យនៃការខ្វះវ៉ាក់សាំង និង ការផ្គត់ផ្គង់វ៉ាក់សាំងឲ្យបានគ្រប់គ្រាន់ និង ទាន់ពេល ។

**(២).សមត្ថភាពក្នុងការអនុវត្តផែនការចាក់វ៉ាក់សាំង** : ចំនួនដ៏ច្រើននៃប្រជាពលរដ្ឋ ដែលត្រូវទទួលបានការចាក់វ៉ាក់សាំង និង រយៈពេលខ្លីនៃយុទ្ធនាការជាតិចាក់វ៉ាក់សាំង អាចបង្កឲ្យមានបញ្ហា-ប្រឈម និង ភាពខ្វះខាតនូវសមត្ថភាពស្ថាប័ន និង ធនធានមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីចូលរួមក្នុងយុទ្ធនាការជាតិចាក់វ៉ាក់សាំង ប្រកបដោយប្រសិទ្ធភាព និង ទាន់ពេល ។ ការណ៍នេះ ទាមទារនូវការត្រៀមរៀបចំឲ្យបានល្អនូវផែនការលម្អិតសម្រាប់អនុវត្ត ក្នុងគ្រប់ទិដ្ឋភាព និង ការកៀរគរ ក៏ដូចជាការប្រើប្រាស់កម្លាំងសរុប និង មធ្យោបាយសរុបរបស់ជាតិ ដើម្បីចូលរួមអនុវត្តយុទ្ធនាការជាតិចាក់វ៉ាក់សាំងនេះ ឲ្យបានប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត។

**(៣). ការកើតឡើង ឬ ការឆ្លងចូលមកកម្ពុជានូវវីរុសកូវីដ-១៩ បំប្លែងថ្មី** : ប្រភេទវីរុសបំប្លែងថ្មី គឺជាក្តីបារម្ភមួយ ដែលអាចធ្វើឲ្យវ៉ាក់សាំងដែលមានស្រាប់បច្ចុប្បន្ននេះ បាត់បង់ ឬ ក៏លែងមានប្រសិទ្ធភាព ។ ការណ៍នេះ ទាមទារឲ្យរាជរដ្ឋាភិបាលបង្កើនការយកចិត្តទុកដាក់ខ្ពស់ដល់ការតាមដាននូវស្ថានការណ៍វិវឌ្ឍនៅតាមបណ្តាប្រទេស ដែលបាន និង កំពុងទទួលរងឥទ្ធិពលខ្លាំងនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងរឹតបន្តឹងវិធានការសុខាភិបាល ក៏ដូចជាវិធានការពាក់ព័ន្ធផ្សេងទៀត ពិសេស ការគ្រប់គ្រងឲ្យបានម៉ត់ចត់លើការចេញ-ចូលរបស់មនុស្ស និង ទំនិញដែលអាចមានហានិភ័យនៃការចម្លងជំងឺកូវីដ-១៩ នៅតាមច្រកទ្វារព្រំដែនអន្តរជាតិ និង ការអនុវត្តដោយម៉ឺងម៉ាត់នូវវិធានចត្តាឡីស័ក្តជាដើម ដើម្បីបញ្ចៀសឱ្យបាននូវការនាំចូលជំងឺកូវីដ-១៩ ប្រភេទថ្មីណាមួយ ដែលអាចចម្លងបន្តទៅដល់សហគមន៍កម្ពុជា ។

## V. សេចក្តីសន្និដ្ឋាន

នៅក្នុងបរិការណ៍ដែលកម្ពុជាបាន និង កំពុងទទួលរងនូវឥទ្ធិពលនៃ «**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១**» ដែលបង្កឲ្យមានភាពអាក់អួលដល់ដំណើរការសង្គម-សេដ្ឋកិច្ចជាតិទាំងមូល ដូចជា ការអនុវត្តវិធានការបិទខ្ទប់ក្នុងទ្រង់ទ្រាយធំ ដែលត្រូវការចំណាយខ្ពស់ និង បង្កផលប៉ះពាល់ច្រើនដល់ជីវភាពរបស់ប្រជាជន, ការសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងការដាក់ចេញនូវ **«ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើតឲ្យបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ក្នុងឆ្នាំ ២០២១»**, គួបផ្សំជាមួយនឹងការជំរុញអនុវត្តវិធានការចាំបាច់ផ្សេងទៀត ជាពិសេស វិធានការ **«៣-កុំ និង ៣-ការពារ»**, គឺពិតជាមានភាពចាំបាច់, បន្ទាន់ និង មានសារៈសំខាន់ដ៏ធំធេង ក្នុងគោលដៅបង្កើតឱ្យបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ច នៅក្នុងឆ្នាំ ២០២១ នៅរាជធានី, ទីរួមខេត្ត និង តំបន់ទីប្រជុំជនធំៗ ដែលជាមជ្ឈមណ្ឌល និង សសៃឈាមសំខាន់ៗនៃសង្គម-សេដ្ឋកិច្ចជាតិ ។

ដោយសារភាពមមាញឹកនៃសកម្មភាពសង្គម-សេដ្ឋកិច្ច ដែលមានភាពប្រទាក់ក្រឡាជាមួយគ្រប់តំបន់ផ្សេងទៀតទូទាំងព្រះរាជាណាចក្រកម្ពុជា, ការចាក់វ៉ាក់សាំងបង្កើតភាពស៊ាំសហគមន៍នៅតាមតំបន់អាទិភាពខ្ពស់ទាំងនេះ គឺជាកិច្ចការអាទិភាពគន្លឹះមួយ ដែលអាចជួយរួមចំណែកគ្រប់គ្រងការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ក្នុងតំបន់នេះខ្លួនឯងផង និង អាចជួយរួមចំណែកទប់ស្កាត់ការឆ្លងរាលដាលទៅកាន់តំបន់ដទៃផង, ហើយលើសពីនេះទៀត, អាចជួយបញ្ចៀសបាននូវការអនុវត្តវិធានការបិទខ្ទប់ក្នុងទ្រង់ទ្រាយធំនាពេលអនាគតផងដែរ ។ ច្បាស់ណាស់ថា ការអនុវត្តផែនការយុទ្ធសាស្ត្រនេះឲ្យសម្រេចបានជោគជ័យក្នុងរយៈពេលដ៏ខ្លី ទាមទារឱ្យមានការគិតគូរគ្រប់ជ្រុងជ្រោយ, ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និង ការប្តេជ្ញាចិត្តចូលរួមយ៉ាងសកម្ម និង ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ពីគ្រប់តួអង្គពាក់ព័ន្ធ ដើម្បីជំនះគ្រប់បញ្ហាប្រឈម និង ឧបសគ្គនានា ដែលអាចកើតមានឡើងជាយថាហេតុ ។ ភាពជោគជ័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ នឹងក្លាយជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយ ក្នុងការប្រយុទ្ធទប់ទល់នឹងផលវិបាកបង្កដោយជំងឺកូវីដ-១៩ និង ជាការបោះជំហានឆ្ពោះទៅរកការធានាបាននូវការស្តារឡើងវិញយ៉ាងឆាប់រហ័ស នៃវិស័យសង្គម-សេដ្ឋកិច្ចកម្ពុជា តាមគន្លង **«ប្រក្រតីភាពថ្មី»** ។

****+****

**(៣). ការកើតឡើង ឬ ការឆ្លងចូលមកកម្ពុជានូវវីរុសកូវីដ-១៩ បំប្លែងថ្មី** : ប្រភេទវីរុសបំប្លែងថ្មីគឺជាក្តីបារម្ភមួយ ដែលអាចធ្វើឲ្យវ៉ាក់សាំងដែលមានស្រាប់បច្ចុប្បន្ននេះ បាត់បង់ ឬ ក៏លែងមានប្រសិទ្ធភាព ។ ការណ៍នេះ ទាមទារឲ្យរាជរដ្ឋាភិបាលបង្កើនការយកចិត្តទុកដាក់ខ្ពស់ដល់ការតាមដាននូវស្ថានការណ៍វិវឌ្ឍនៅតាមបណ្តាប្រទេស ដែលបាន និង កំពុងទទួលរងឥទ្ធិពលខ្លាំងនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងរឹតបន្តឹងវិធានការសុខាភិបាល ក៏ដូចជាវិធានការពាក់ព័ន្ធផ្សេងទៀត ពិសេស ការ-គ្រប់គ្រងឲ្យបានម៉ត់ចត់លើការចេញ-ចូលរបស់មនុស្ស និង ទំនិញដែលអាចមានហានិភ័យនៃការចម្លងជំងឺកូវីដ-១៩ នៅតាមច្រកទ្វារព្រំដែនអន្តរជាតិ និង ការអនុវត្តដោយម៉ឺងម៉ាត់នូវវិធានចត្តាឡីស័ក្តជាដើម ដើម្បីបញ្ចៀសឱ្យបាននូវការនាំចូលជំងឺកូវីដ-១៩ ប្រភេទថ្មីណាមួយ ដែលអាចចម្លងបន្តទៅដល់សហគមន៍កម្ពុជា ។

## V. សេចក្តីសន្និដ្ឋាន

នៅក្នុងបរិការណ៍ដែលកម្ពុជាបាន និង កំពុងទទួលរងនូវឥទ្ធិពលនៃ «**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១**» ដែលបង្កឲ្យមានភាពអាក់រអួលដល់ដំណើរការសង្គម-សេដ្ឋកិច្ចជាតិទាំងមូល ដូចជា ការអនុវត្តវិធានការបិទខ្ទប់ក្នុងទ្រង់ទ្រាយធំ ដែលត្រូវការចំណាយខ្ពស់ និង បង្កផលប៉ះពាល់ច្រើនដល់ជីវភាពរបស់ប្រជាជន, ការសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងការដាក់ចេញនូវ «**ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើតឲ្យបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ក្នុងឆ្នាំ ២០២១**», គួបផ្សំជាមួយនឹងការជំរុញអនុវត្តវិធានការចាំបាច់ផ្សេងទៀត ជាពិសេស វិធានការ «**៣-កុំ និង ៣-ការពារ**», គឺពិតជាមានភាពចាំបាច់, បន្ទាន់ និង មានសារៈសំខាន់ដ៏ធំធេង ក្នុងគោលដៅបង្កើតឱ្យបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ច នៅក្នុងឆ្នាំ ២០២១ នៅរាជធានី, ទីរួមខេត្ត និង តំបន់ទីប្រជុំជនធំៗ ដែលជាមជ្ឈមណ្ឌល និង សសៃឈាមសំខាន់ៗនៃសង្គម-សេដ្ឋកិច្ចជាតិ ។

ដោយសារភាពមមាញឹកនៃសកម្មភាពសង្គម-សេដ្ឋកិច្ច ដែលមានភាពប្រទាក់ក្រឡាជាមួយគ្រប់តំបន់ផ្សេងទៀតទូទាំងព្រះរាជាណាចក្រកម្ពុជា, ការចាក់វ៉ាក់សាំងបង្កើតភាពស៊ាំសហគមន៍នៅតាមតំបន់អាទិភាពខ្ពស់ទាំងនេះ គឺជាកិច្ចការអាទិភាពគន្លឹះមួយ ដែលអាចជួយរួមចំណែកគ្រប់គ្រងការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ក្នុងតំបន់នេះខ្លួនឯងផង និង អាចជួយរួមចំណែកទប់ស្កាត់ការឆ្លងរាលដាលទៅកាន់តំបន់ដទៃផង, ហើយលើសពីនេះទៀត, អាចជួយបញ្ចៀសបាននូវការអនុវត្តវិធានការបិទខ្ទប់ក្នុងទ្រង់ទ្រាយធំនាពេលអនាគតផងដែរ ។ ច្បាស់ណាស់ថា ការអនុវត្តផែនការយុទ្ធសាស្ត្រនេះឲ្យសម្រេចបានជោគជ័យក្នុងរយៈពេលដ៏ខ្លី ទាមទារឱ្យមានការគិតគូរគ្រប់ជ្រុងជ្រោយ, ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និង ការប្តេជ្ញាចិត្តចូលរួមយ៉ាងសកម្ម និង ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ពីគ្រប់តួអង្គពាក់ព័ន្ធ ដើម្បីជំនះគ្រប់បញ្ហាប្រឈម និង ឧបសគ្គនានា ដែលអាចកើតមានឡើងជាយថាហេតុ ។ ភាពជោគជ័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ នឹងក្លាយជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយ ក្នុងការប្រយុទ្ធទប់ទល់នឹងផលវិបាកបង្កដោយជំងឺកូវីដ-១៩ និង ជាការបោះជំហានឆ្ពោះទៅរកការធានាបាននូវការស្តារឡើងវិញយ៉ាងឆាប់រហ័ស នៃវិស័យសង្គម-សេដ្ឋកិច្ចកម្ពុជា តាមគន្លង «**ប្រក្រតីភាពថ្មី**» ។

* * * * + * * * *

# ឧបសម្ព័ន្ធទី ១

## តារាងទី ១: យុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ តាមតំបន់អាទិភាព (តាមរាជធានី ខេត្ត)

## សំដៅបង្កើតឲ្យបាននូវភាពស៊ាំសហគមន៍នៅកម្ពុជា

(បច្ចុប្បន្នភាពតារាង គិតត្រឹមថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០២១)

| | | | | | តំបន់អាទិភាពខ្ពស់ | | | តំបន់អាទិភាពមធ្យម | | | តំបន់អាទិភាពទាប | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
